ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍បូកសរុប

## ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ប្រចាំឆ្នាំ២០១៧-២០១៨ និងទិសដៅការងារសម្រាប់ឆ្នាំ២០១៨-២០១៩



**សន្និបាតកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨**

# មាតិកា

**I- សេចក្តីផ្តើម**........................................1
**II- គោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម**........................................5
**III- លទ្ធផលជារួម** ........................................14
**IV- លទ្ធផលតាមអនុវិស័យ** ........................................17
១. លទ្ធផលនៃការលើកកម្ពស់ផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ........................................18
២. ការជំរុញផលិតកម្មសត្វ និងសុខភាពសត្វ........................................40
៣. លទ្ធផលនៃការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព ........................................49
៤. លទ្ធផលនៃការគ្រប់គ្រងព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តរភាព........................................53
៥. លទ្ធផលនៃការពង្រឹងស្ថាប័ន ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស ........................................59
**V- បញ្ហាប្រឈម**........................................87
**VI- ទិសដៅអនុវត្តឆ្នាំ២០១៨-២០១៩**........................................88
១. ផែនការផលិតកម្មដំណាំស្រូវ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម ........................................88
២. ផែនការផលិតកម្មដំណាំកៅស៊ូ ........................................89
៣. ផែនការលើកកម្ពស់សុខភាពសត្វ និងផលិតកម្មសត្វ........................................90
៤. ផែនការផ្នែកជលផល........................................91
៥. ផែនការផ្នែកព្រៃឈើ ........................................92
**VII- សេចក្តីសន្និដ្ឋាន** ........................................93
**ឧបសម្ព័ន្ធ**

# របាយការណ៍បូកសរុប
# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៧-២០១៨
# និងទិសដៅអនុវត្តឆ្នាំ២០១៨-២០១៩

## I- សេចក្ដីផ្ដើម

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយ និងជំរុញការអនុវត្ត **"យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨"** ដែលនៅតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាព ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ធានាសមធម៌ ធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដោយបានកំណត់យ៉ាងច្បាស់ថា ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ការកែទម្រង់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ពិសេសធនធានព្រៃឈើនិងជលផល គឺជាមុខព្រួញស្នូលដ៏សំខាន់ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

អនុវត្តតាមគោលនយោបាយនិងយុទ្ធសាស្ត្រនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការបន្តធ្វើទំនើបកម្មវិស័យកសិកម្ម តាមរយៈការបង្កើនផលិតភាព ការធ្វើពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ដោយបានជំរុញការអនុវត្តវិធានការចាំបាច់មួយចំនួនរួមមានៈ ការកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ ដែលបម្រើដល់ផលិតកម្មកសិកម្ម បង្កើនការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករ ការស្រាវជ្រាវបច្ចេកទេសកសិកម្ម សំដៅបង្កើនទិន្នផលដំណាំនិងបន្សាំការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងនិងបង្កើនជីជាតិដីកសិកម្ម ការពង្រឹងសហគមន៍កសិកម្ម ព្រមទាំងការកសាងនិងពង្រឹងសមត្ថភាពធនធានមនុស្សនិងស្ថាប័ន ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្ម។ ទន្ទឹមនឹងនេះ ក្រសួងក៏បានយកចិត្តទុកដាក់ខ្ពស់អំពីការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ព្រមទាំងខិតខំយ៉ាងខ្លាំងក្លាលើការអនុវត្តវិធានការច្បាប់ និងវិធានការបច្ចេកទេសសមស្រប ក្នុងការគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិ ព្រៃឈើនិងជលផលប្រកបដោយចីរភាព។ ការខិតខំប្រឹងប្រែងទាំងអស់នេះ គឺក្នុងទិសដៅចូលរួមចំណែកបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ក៏ដូចជាការជួយបង្កើនប្រាក់ចំណូលជូនប្រជាកសិករ ការបន្តជំរុញការធ្វើកសិពាណិជ្ជកម្ម និងការបង្កើនចំណូលជាតិ។

គួរកត់សម្គាល់ថា បច្ចុប្បន្ននេះ ផលិតកម្មដំណាំស្រូវមានការវិវឌ្ឍឈានឡើងជាលំដាប់ គឺអាស្រ័យដោយមានការគាំទ្រយ៉ាងខ្លាំងក្លាពីរាជរដ្ឋាភិបាលកម្ពុជា ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍នានា អង្គការជាតិ និងអន្តរជាតិ អាជ្ញាធរថ្នាក់ក្រោមជាតិ និងការចូលរួមយ៉ាងសកម្មពីប្រជាកសិករ ជាពិសេសការប្តូរទម្លាប់ពីការផលិតសម្រាប់ហូបចុកមកជាការផលិតសម្រាប់ពាណិជ្ជកម្ម។ ការសម្រេចបានក្នុងការបង្កើនផលិតភាពដំណាំស្រូវបណ្តាលមកពីកត្តាសំខាន់ៗមួយចំនួនដូចជា ការផ្លាស់ប្តូរពូជស្រូវដែលមានទិន្នផលខ្ពស់ ដែលជាលទ្ធផលទទួលបានពីការពិសោធន៍ស្រាវជ្រាវ ការផ្ទេរបច្ចេកទេសសមស្របដល់កសិករ ជាពិសេស ការពង្រីកកាន់តែមានប្រសិទ្ធភាពលើការធ្វើស្រែបង្ហាញតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ ការអនុវត្តបច្ចេកទេសគ្រប់គ្រងដីដើម្បីបង្កើនជីជាតិនិងទិន្នផល ការបង្កើនការស្រាវជ្រាវនិងអភិវឌ្ឍពូជស្រូវដែលស្របនឹងលក្ខណៈដី អាកាសធាតុ ការកំណត់ប្រភេទពូជសំខាន់ៗស្របតាមតម្រូវការទីផ្សារ។

ការធ្លាក់ចុះនៃថ្លៃស្រូវក្នុងពេលប្រមូលផល បានកើតមានជារៀងរាល់ឆ្នាំ និងបានធ្វើឱ្យកសិករទទួលរងផលប៉ះពាល់គួរឱ្យកត់សម្គាល់។ ជាការឆ្លើយតប ក្រសួងបានដាក់ចេញនូវវិធានការបន្ទាន់មួយចំនួន ដោយបានស្នើឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត សហការជាមួយអាជ្ញាធរខេត្ត រួមនឹងស្ថាប័នពាក់ព័ន្ធ ចុះពិនិត្យជាក់ស្តែង

ដល់មូលដ្ឋាន ដើម្បីទប់ស្កាត់ការប្រមូលទិញផ្តាច់មុខពីសំណាក់ឈ្មួញនៅតាមតំបន់ និងធ្វើការចរចាជាមួយសហគមន៍រោងម៉ាស៊ីនកិនស្រូវតាមបណ្តាខេត្ត ដើម្បីប្រមូលទិញស្រូវពីកសិករឱ្យអស់លទ្ធភាពក្នុងតម្លៃសមស្រប។ ឆ្លើយតបទៅនឹងបញ្ហាតម្លៃស្រូវធ្លាក់ចុះនេះផងដែរ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសអន្តរាគមន៍ក្នុងការប្រមូលទិញស្រូវដោយបង្កើនឥណទានដល់៥០លានដុល្លារ សម្រាប់ប្រមូលទិញស្រូវ។ បន្ថែមលើនេះ រាជរដ្ឋាភិបាលបានពង្រឹងនីតិវិធីនាំចូលផលិតផលកសិកម្មពីប្រទេសជិតខាង និងស្នើឱ្យមានការសម្របសម្រួលចរចាជាមួយប្រទេសដៃគូពាណិជ្ជកម្មដើម្បីនាំចេញអង្ករឬផលិតផលកសិកម្មពីកម្ពុជា។

គោលនយោបាយ ស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ដែលត្រូវបានដាក់ចេញនៅក្នុងឆ្នាំ២០១០ កន្លងទៅ បានកំណត់នូវគោលដៅសំខាន់ៗចំនួន០៣គឺ៖ ១)- បង្កើនផលិតផលស្រូវលើសពីសេចក្តីត្រូវការឱ្យដល់៤លានតោន ២)- ជំរុញការនាំចេញអង្ករឱ្យបានយ៉ាងតិច១លានតោន ៣)- ធ្វើឱ្យអង្ករកម្ពុជាត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅឆ្នាំ២០១៥។ ទោះបីយើងមិនទាន់អាចសម្រេចបាននូវការនាំអង្ករចេញ១លានតោន គិតមកទល់នឹងពេលនេះក្តី តែយើងបានសម្រេចធ្វើឱ្យអង្ករកម្ពុជាត្រូវបានទទួលស្គាល់ជាអន្តរជាតិ ហើយផលិតផលស្រូវលើសពីសេចក្តីត្រូវការបានកើនឡើងដល់ប្រមាណជាង៥លានតោននៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលបានក្លាយជាប្រភពដ៏សំខាន់ នៅក្នុងការធានាបាននូវស្ថិរភាពនៃប្រភពស្រូវ ដើម្បីធ្វើការកែច្នៃសម្រាប់នាំអង្ករចេញ។ ទន្ទឹមនឹងនេះ ប្រព័ន្ធខ្សែចង្វាក់ស្រូវអង្ករកម្ពុជា ក៏បានបង្កើតនូវស្ថានភាពមួយ ដែលតួអង្គពាក់ព័ន្ធទាំងអស់កាន់តែមានការយល់ដឹង និងសមត្ថភាពជំនាញ ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ពង្រីកលទ្ធភាពនាំចេញរបស់កម្ពុជាទៅថ្ងៃមុខតាមរយៈការដោះស្រាយនូវបញ្ហាប្រឈមនានា និងពង្រឹងភាពទន់ខ្សោយរបស់កម្ពុជានៅក្នុងប្រព័ន្ធខ្សែចង្វាក់កែច្នៃអង្ករទាំងមូល។

ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលបានសម្រេចដាក់ចុះនូវយន្តការអន្តរាគមន៍រយៈពេលខ្លី ដើម្បីដោះស្រាយបញ្ហាហេដ្ឋារចនាសម្ព័ន្ធឡសម្ងួតនិងឃ្លាំងស្តុកស្រូវ ក៏ដូចជាទុនបង្វិល ដើម្បីការពារផលប្រយោជន៍កសិករ តាមរយៈការការពារស្ថិរភាពនៃថ្លៃស្រូវ គឺទ្រទ្រង់ថ្លៃស្រូវកុំឱ្យធ្លាក់ចុះខ្លាំងពេក ហួសពីថ្លៃទីផ្សារដោយមិនសមហេតុផល។ អន្តរាគមន៍នេះ រួមមាន៖ ទី១)- បង្កើនការវិនិយោគលើមជ្ឈមណ្ឌលប្រមូលទិញស្រូវ ដែលរួមមានការសាងសង់ឃ្លាំងស្តុកស្រូវ និងឡសម្ងួតដល់ប្រមាណ ៣០លានដុល្លារអាមេរិក ដោយផ្តោតលើតំបន់ផលិតស្រូវសំខាន់ៗ ដើម្បីស្រូបយកផលស្រូវពីកសិករ នៅពេលគាត់មានតម្រូវការនៅក្នុងការលក់បន្ទាប់ពីគាត់ធ្វើការប្រមូលផលរួច។ ទី២)-បង្កើនឥណទានប្រមូលទិញស្រូវឱ្យកើនឡើងដល់ ៥០លានដុល្លារអាមេរិក ដោយធនាគារអភិវឌ្ឍន៍ជនបទដើរតួជាប្រតិបត្តិករក្នុងការផ្តល់ឥណទានដល់រោងម៉ាស៊ីនកិនស្រូវធំៗប្រើប្រាស់ជាទុនបង្វិលសម្រាប់ប្រមូលទិញស្រូវ ជាមួយនឹងនីតិវិធីផ្តល់ឥណទានឆាប់រហ័ស និងមានអត្រាការប្រាក់៥%ក្នុងមួយឆ្នាំ។ ទី៣)- ដោយសារការដឹកជញ្ជូន ក៏ជះឥទ្ធិពលដល់ការលក់ស្រូវរបស់កសិករ រាជរដ្ឋាភិបាលនឹងបង្កើនការវិនិយោគបន្ថែមលើការសាងសង់ផ្លូវដើម្បីភ្ជាប់ទៅទីផ្សារ។ ទី៤)- សម្រួលច្រកព្រំដែនជាមួយប្រទេសជិតខាង ដើម្បីឱ្យយើងអាចធ្វើការនាំចេញស្រូវ ក៏ដូចជាកសិកផលផ្សេងទៀតទៅប្រទេសជិតខាងដោយងាយស្រួលនិងមិនមានការរាំងស្ទះ តាមរយៈសម្រួលនីតិវិធីបែបបទការនាំចេញ និងការបន្តខិតខំកាត់បន្ថយថ្លៃដឹកជញ្ជូន រួមទាំងចំណាយផ្លូវការនិងក្រៅផ្លូវការ។ ទី៥)- បន្តខិតខំស្វែងរកទីផ្សារក្រៅប្រទេសថ្មីៗថែមទៀត ដើម្បីជំរុញការនាំអង្ករចេញ ជាពិសេសទៅកាន់ប្រទេសទីផ្សារគោលដៅសំខាន់ៗ រួមទាំងទីផ្សារប្រទេសចិន និងទីផ្សារសក្តានុពលមួយចំនួនទៀត។

នាពេលកន្លងទៅនេះ ក្រសួងបានប្រកាសដាក់ឲ្យប្រើប្រាស់នូវឯកសារ "គោលនយោបាយផ្សព្វផ្សាយកសិកម្ម **នៅកម្ពុជា**" ដើម្បីឲ្យកសិករនិងសហគមន៍កសិករទទួលបាន និងប្រើប្រាស់ចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មបានល្អប្រសើរ។ បន្ថែមលើនេះ ក្រោយពីរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយស្តីពី "**ការជំរុញផលិតកម្មស្រូវ និង ការនាំចេញអង្ករ**" បរិមាណអង្ករនាំចេញបានកើនឡើងទៅកាន់ទីផ្សារអន្តរជាតិ និងអង្ករពូជស្រូវផ្ការំដួលត្រូវបានចាត់ទុកថាមានគុណភាពល្អជាងគេក្នុងពិភពលោក។

ការបង្វែរទិសពីការអភិវឌ្ឍតាមបែបទូលាយ ឬតាមបែបវិបុលកម្មទៅកាន់ការអភិវឌ្ឍតាមបែបស៊ីជម្រៅ ឬតាមបែបប្រពលវប្បកម្ម ពោលគឺការពង្រីកសមត្ថភាពផលិតលើផ្ទៃដីដែលមានស្រាប់ តាមរយៈប្រពលវប្បកម្ម និងការបង្កើនរដូវដាំដុះបានក្លាយជារបៀបវារៈអាទិភាពមួយដ៏សំខាន់។ ជាកត្តាសត្យានុម័ត ការពង្រីកនិងការពង្រឹងសេវាកម្មគាំទ្រដ៏មានប្រសិទ្ធភាព ដូចជាការស្រាវជ្រាវ ការផ្សព្វផ្សាយនូវបច្ចេកវិទ្យាទំនើបទៅតាមអនុវិស័យ អាស្រ័យទៅតាមសក្តានុពលនៃភូមិសាស្ត្រ ការបែងចែកពូជ ជី សម្ភារកសិកម្ម និងការផ្តល់ឥណទានជនបទត្រូវបានយកចិត្តទុកដាក់ និងជាអាទិភាពរបស់រាជរដ្ឋាភិបាល សំដៅលើកកម្ពស់ផលិតភាពកសិកម្ម ឆ្លើយតបទៅតាមតម្រូវការទីផ្សារ ទាំងបរិមាណ គុណភាព សុវត្ថិភាព និងស្តង់ដារអន្តរជាតិ។

បច្ចុប្បន្ននេះ យើងបានកត់សម្គាល់ថា ប្រជាកសិករយើងកំពុងប្រែប្រួលទម្លាប់ ពីការផលិតសម្រាប់បម្រើសេចក្តីត្រូវការផ្ទាល់ខ្លួន មកជាការផលិតដើម្បីលក់ ព្រោះមានតម្រូវការទីផ្សារខ្ពស់។ ផ្អែកលើការប្រែប្រួលនេះ យើងអាចសន្និដ្ឋានបានថា សហគមន៍កសិកម្មកំពុងក្លាយជាកម្លាំងចលករមួយយ៉ាងសំខាន់ ដែលនាំឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងសង្គមជនបទកម្ពុជា។ នេះបង្ហាញឱ្យឃើញថា កសិករយើងបាននិងកំពុងប្រែក្លាយខ្លួនចេញពី "កសិករទៅជាកសិ-ពាណិជ្ជករ" ដើម្បីទទួលបានតម្លៃបន្ថែមក្នុងជីវភាពរស់នៅរបស់ខ្លួន។ ក្នុងបរិបទនេះ យើងសង្កេតឃើញថា មានស្ថាប័នជាច្រើនទាំងរដ្ឋ វិស័យឯកជន និងអង្គការក្រៅរដ្ឋាភិបាលបាននិងកំពុងផ្តល់សេវាកម្ម ដើម្បីបង្កើនចំណេះដឹង និងចំណេះធ្វើដល់កសិករនៅមូលដ្ឋាន ហើយក៏មានកសិករជាច្រើនបានក្រេបជញ្ជក់ យកបទពិសោធន៍ និងទេពកោសល្យទាំងអស់នេះយកទៅអនុវត្ត ប្រកបដោយភាពឧស្សាហ៍ព្យាយាមនិងច្នៃប្រឌិត ដោយទទួលបានលទ្ធផលជាផ្លែផ្កាយ៉ាងត្រចះត្រចង់ នៅក្នុងតំបន់ជាច្រើនទៅតាមអនុវិស័យនីមួយៗ។

សន្ទុះនៃការដាំដុះកៅស៊ូនៅកម្ពុជាមានការកើនឡើងជាលំដាប់ អាស្រ័យដោយស្ថានភាពនយោបាយ សន្តិសុខល្អប្រសើរ សក្តានុពលនៃដីសមស្រប និងគោលនយោបាយទីផ្សារសេរី លើការលក់ដូរផលិតផលកៅស៊ូគ្រួសារក្នុងស្រុក។ ទន្ទឹមនឹងនេះ មានការចូលរួមពីផ្នែកឯកជន ក្នុងការធ្វើវិនិយោគលើដីសម្បទានសេដ្ឋកិច្ច និងផ្នែកកៅស៊ូគ្រួសារ ដែលបានធ្វើឱ្យផ្ទៃដីដាំដុះកៅស៊ូកើនឡើងគួរឱ្យកត់សម្គាល់។

ផលិតកម្មសត្វទាំងលក្ខណៈគ្រួសារនិងពាណិជ្ជកម្មនៅកម្ពុជា ក៏មានការវិវឌ្ឍគួរឲ្យកត់សម្គាល់ ទាំងបរិមាណសត្វ និងបែបផែនផលិតកម្ម។ ការរីកចម្រើនទាំងអស់នេះ គឺជាលទ្ធផលនៃការស្រាវជ្រាវ និងការយល់ដឹងអំពីបច្ចេកទេសចិញ្ចឹមសត្វ ការជ្រើសរើសនិងការបង្កាត់ពូជសត្វ ការផលិតចំណីសត្វ និងការផ្តល់សេវាថែទាំសុខភាពសត្វ។ ជាមួយគ្នានេះ ច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ដែលបានប្រកាសដាក់ឱ្យអនុវត្តកាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ត្រូវបាននិងកំពុងអនុវត្តយ៉ាងមានប្រសិទ្ធភាព ព្រមទាំងបានជំរុញការអភិវឌ្ឍផ្នែកផលិតកម្មសត្វ និងសុខភាពសត្វនៅកម្ពុជាផងដែរ។ ពិសេសជាងនេះទៀតនោះ ការទប់ស្កាត់ចលនាសត្វខុសច្បាប់ត្រូវបានអនុវត្តយ៉ាងយកចិត្តទុកដាក់ ហើយការទប់ស្កាត់ជំងឺឆ្លងសត្វក៏ត្រូវបានពង្រឹងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ការកែទម្រង់ស៊ីជម្រៅវិស័យជលផលត្រូវបន្តបានអនុវត្តយ៉ាងសកម្ម។ កំណែទម្រង់នេះ បានធ្វើឱ្យប្រជាជនទូទៅ ជាពិសេសអ្នកប្រកបរបរនេសាទជាលក្ខណៈគ្រួសារ អាចធ្វើអាជីវកម្មបានទូលំទូលាយជាងមុន។ រហូតមកដល់ពេលនេះ យើងបានបង្កើតសហគមន៍នេសាទចំនួន៥១៦ ដើម្បីគ្រប់គ្រងធនធានជលផលឱ្យមាននិរន្តរភាព។ សព្វថ្ងៃនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងខិតខំអនុវត្តទិសស្លោក "សហគមន៍នេសាទគ្មានបទល្មើស" ក្នុងគោលបំណងពង្រឹងសហគមន៍នេសាទឱ្យបានរឹងមាំ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចូលរួមគ្រប់គ្រងថែរក្សាការពារធនធានជលផលឱ្យបានគង់វង្ស។ ជាការកែទម្រង់ថ្មីមួយទៀត ក្រសួងបានបើកឱ្យមានការចិញ្ចឹមត្រីរ៉ស់ និងត្រីឆ្តោឡើងវិញ ទាំងជាលក្ខណៈគ្រួសារនិងពាណិជ្ជកម្ម ហើយការចិញ្ចឹមនេះ ត្រូវភ្ជាប់ជាមួយលក្ខខណ្ឌមួយចំនួន ដើម្បីងាយស្រួលគ្រប់គ្រង និងផ្តល់បច្ចេកទេស និងជាពិសេសទៀតនោះ គឺសំដៅធានាឱ្យបាននូវការអនុវត្តស្របតាមបទដ្ឋានបច្ចេកទេសសមស្រប ធានានិរន្តរភាពធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ីនិងបរិស្ថាន។ ជាលទ្ធផលជាក់ស្តែង ការចិញ្ចឹមត្រីមានការកើនឡើងរហូតដល់ជាង២០% បើប្រៀបធៀបនឹងឆ្នាំមុន។

ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ លើកម្មវិធីកំណែទម្រង់វិស័យព្រៃឈើ ដោយខិតខំបង្កើនសមត្ថភាពបច្ចេកទេស សំដៅជំរុញការងារគ្រប់គ្រងឱ្យមានប្រសិទ្ធភាពខ្ពស់ និងពិសេសយកចិត្តទុកដាក់ជាសំខាន់លើការត្រួតពិនិត្យតាមដានដ៏តឹងរ៉ឹង ព្រមទាំងសម្រេចបាននូវលទ្ធផលមួយចំនួនផងដែរ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកត់សម្គាល់ឃើញអំពីការចូលរួមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានា។ លើសពីនេះទៀត ក្រសួងក៏បានចូលរួមអនុវត្តយ៉ាងសកម្មជាមួយគណៈកម្មការជាតិ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើរបស់រាជរដ្ឋាភិបាលកម្ពុជា សំដៅទប់ស្កាត់និងបង្ក្រាបសកម្មភាពអនាធិបតេយ្យកាប់ឈើ ការនាំចេញឈើខុសច្បាប់ និងបទល្មើសនានានៅភាគឦសាន្តនៃប្រទេស។

ជាការកែទម្រង់មួយថ្មីទៀត ក្រសួងបានដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផល ឱ្យស្ថិតនៅក្រោមមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត។ បន្ថែមពីនេះទៀតនោះ ក្រសួងក៏បានផ្ទេរធនធាននិងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលនៃខណ្ឌ ផ្នែក សង្កាត់ រដ្ឋបាលព្រៃឈើនិងរដ្ឋបាលជលផល ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្ត។ ជាមួយគ្នានេះ ក្រសួងបានវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងបំពេញភារកិច្ចប្រកបដោយស្មារតីយកចិត្តទុកដាក់មិនខ្លាចនឿយហត់ និងការលះបង់ខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃរដ្ឋបាលជលផលនិងរដ្ឋបាលព្រៃឈើ ដែលបានខិតខំតស៊ូបំពេញភារកិច្ចរបស់ខ្លួនបានល្អប្រសើរក្នុងរយៈពេល១ឆ្នាំកន្លងមក ជាពិសេសការខិតខំប្រឹងប្រែងក្នុងឱកាសដែលរាជរដ្ឋាភិបាលកំពុងធ្វើកំណែទម្រង់ស៊ីជម្រៅក្នុងវិស័យទាំងពីរនេះ ដែលនេះជាសក្ខីភាពបង្ហាញឱ្យឃើញនូវការចូលរួមចំណែកក្នុងបុព្វហេតុនៃការលើកកម្ពស់ផ្នែកជលផល និងព្រៃឈើនៅកម្ពុជា ឲ្យមានការរីកចម្រើនជាលំដាប់ប្រកបដោយមោទនភាព។ ទន្ទឹមនឹងនេះ ក្រសួងក៏សូមវាយតម្លៃខ្ពស់ ចំពោះកិច្ចសហការល្អ និងការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដែលបានរួមចំណែកយ៉ាងសកម្មក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានជលផល និងព្រៃឈើប្រកបដោយនិរន្តរភាព ជាពិសេសការបង្ក្រាបបទល្មើសតាមគ្រប់រូបភាពឱ្យទទួលបានលទ្ធផលល្អប្រសើរ ទោះបីនៅមានបញ្ហាប្រឈមខ្លះៗក៏ដោយ។ ជាការកត់សម្គាល់ ប្រសិទ្ធភាពនៃការគ្រប់គ្រងក្នុងអនុវិស័យទាំងពីរនេះ ត្រូវបានវាយតម្លៃថាមានការកើនឡើងគួរជាទីពេញចិត្ត។

ក្នុងគោលបំណងជំរុញការងាររៀបចំកំណត់តំបន់ដាំដុះកសិកម្ម ឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតគណៈកម្មាធិការកំណត់តំបន់ដាំដុះកសិកម្ម តាមរយៈសេចក្តីសម្រេចលេខ ៦៧៩ សសរ.កសក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧។ គណៈកម្មាធិការនេះ ដឹកនាំដោយឯកឧត្តមអនុរដ្ឋ លេខាធិការនៃក្រសួង និងមានសមាសភាពចូលរួមពីថ្នាក់ដឹកនាំ រួមទាំងអង្គភាពជំនាញពាក់ព័ន្ធចំនួន១៦រូប។ ក្នុងកិច្ចដំណើរការនៃការរៀបចំ គណៈកម្មាធិការកំណត់តំបន់ដាំដុះកសិកម្ម បានរៀបចំកិច្ចប្រជុំលើកទី១ កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ ដើម្បីជំរុញការអនុវត្តស្របតាមតួនាទី និងភារកិច្ចដែលបានប្រគល់ជូន។ គណៈកម្មាធិការនេះ បានពិនិត្យ និងសិក្សាឡើងវិញអំពីទិន្នន័យពាក់ព័ន្ធនឹងព័ត៌មានដីកសិកម្ម ដែលរួមមាន៖ (១) ផែនទីដីរបស់លោក Crocker ឆ្នាំ១៩៦២ (២) ផែនទីប្រព័ន្ធអេកូឡូស៊ីស្រូវ (Rice Ecosystem Map) (៣) ផែនទីចំណាត់ថ្នាក់ដី និងផែនទីប្រើប្រាស់ដី ដែលនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម បានផលិតក្នុងស្រុកគោលដៅចំនួន១0នៃខេត្តសំខាន់ៗ (៤)ទិន្នន័យ ផ្កាយរណបរបស់អង្គការណាសា (NASA Satellite Data) និង (៥) ឯកសារបច្ចេកទេសដីរបស់អង្គការ FAO (Framework for Land Evaluation)។ សម្រាប់ការងារបន្ទាប់ គណៈកម្មាធិការនេះនឹងរៀបចំឯកសារទស្សនទានកំណត់ការងារ ជំហានដែលត្រូវធ្វើ និងសេចក្តីត្រូវការធនធានផ្សេងៗ ព្រមទាំងមាតិកានៃឯកសារស្តីពីការកំណត់តំបន់ដាំដុះកសិកម្ម។

## II- គោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម

### ១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨នេះ គឺជាឯកសារផែនការគោលនយោបាយ និងយុទ្ធសាស្ត្រមួយដ៏សំខាន់សម្រាប់រយៈពេលមធ្យម និងជាផែនទីបង្ហាញផ្លូវ ដែលបានកំណត់ច្បាស់អំពីទិសដៅអភិវឌ្ឍន៍វិស័យកសិកម្ម ជាមួយនឹងគោលបំណង លទ្ធផលរំពឹងទុក សូចនាករ និងចង្កោមសកម្មភាព របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់អនុវត្តក្នុងរយៈពេល៥ឆ្នាំពីឆ្នាំ២០១៤ដល់ឆ្នាំ២០១៨ និងបានឆ្លុះបញ្ចាំងពីគោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេស យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ សំដៅរួមចំណែកដល់ការរីកចម្រើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំសម្រាប់អនុវត្ត ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការធ្វើទំនើបកម្មវិស័យកសិកម្មកម្ពុជា ទៅតាមអភិក្រមក្នុងវិសាលភាព និងល្បឿនថ្មី សំដៅជំរុញការរីកលូតលាស់សេដ្ឋកិច្ចកសិកម្ម និងការនាំចេញផលិតផលកសិកម្ម រួមនឹងការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

ការកំណត់ទិសដៅគោលនយោបាយរួមរបស់ក្រសួងសម្រាប់អនុវត្តរយៈពេល៥ឆ្នាំគឺ *"ជំរុញកំណើនកសិកម្មប្រចាំឆ្នាំឱ្យបានក្នុងរង្វង់៥% តាមរយៈការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ការលើក កម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ដោយយកចិត្តទុកដាក់ខ្ពស់លើការការពារ និងគ្រប់គ្រងធនធានធម្មជាតិព្រៃឈើនិងជលផលប្រកបដោយចីរភាព"*។

ដើម្បីសម្រេចបានទិសដៅគោលនយោបាយនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតកម្មវិធីយុទ្ធសាស្ត្រចំនួន៥ ដូចខាងក្រោមនេះ៖

#### កម្មវិធីទី ១៖ បង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម

ជំរុញកំណើនផលិតកម្មគ្រប់មុខដំណាំក្នុងរង្វង់១០%ក្នុងមួយឆ្នាំ តាមរយៈការបង្កើនការស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្មសំដៅបង្កើនទិន្នផលដំណាំ លើកកម្ពស់ផលិតភាព គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម និងអង្គការកសិករនានា ដោយផ្សារភ្ជាប់ជាមួយផលិតកម្មកសិកម្មតាមកិច្ចសន្យា និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងប្រើប្រាស់ដីកសិកម្មប្រកបដោយនិរន្តរភាព។

#### កម្មវិធីទី ២៖ ជំរុញផលិតកម្មសត្វ និងសុខភាពសត្វ

ជំរុញការចិញ្ចឹមសត្វក្នុងអត្រាកំណើន៣%ក្នុងមួយឆ្នាំ ដោយផ្អែកលើប្រសិទ្ធភាពនៃការពិសោធន៍ស្រាវជ្រាវ និងផ្សព្វផ្សាយ បង្កើនសមត្ថភាពបង្ការទប់ស្កាត់ជំងឺឆ្លងសត្វ និងជំងឺសូណូស៊ីស ធានាការផ្គត់ផ្គង់សត្វ ផលិតផលសត្វ ប្រកបដោយអនាម័យ សុវត្ថិភាព និងបង្កើនសក្តានុភាពនៃការនាំចេញ។

#### កម្មវិធីទី ៣៖ ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព

បង្កើនការការពារ និងអភិរក្សធនធានជលផល ដោយលុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព ពង្រឹងសមត្ថភាពគ្រប់គ្រង១០០សហគមន៍នេសាទ និងជំរុញការអភិវឌ្ឍវារីវប្បកម្មក្នុងកំណើន១៥%រៀងរាល់ឆ្នាំ ដើម្បីធានាឱ្យបាននូវនិរន្តរភាពធនធានជលផល ព្រមទាំងកែលម្អគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផល សម្រាប់ការប្រើប្រាស់ក្នុងស្រុកនិងនាំចេញ។

#### កម្មវិធីទី ៤៖ ការគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព

បង្កើនការគ្រប់គ្រងព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ជំរុញការដាំឈើឡើងវិញ បង្កើនតំបន់អភិរក្សសត្វព្រៃ និងសហគមន៍ព្រៃឈើឱ្យបាន២០សហគមន៍ក្នុង១ឆ្នាំ។

#### កម្មវិធីទី ៥៖ ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស

បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្តល់សេវាគាំទ្រនិងពង្រឹងសមត្ថភាពផ្នែកអប់រំ និងបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព។

ដើម្បីសម្រេចបាននូវទិសដៅគោលនយោបាយទាំងអស់ខាងលើ ការងារជាច្រើនត្រូវបានអនុវត្ត និងវាយតម្លៃថាសម្រេចបានលទ្ធផលគួរជាទីពេញចិត្ត។ គ្រប់អង្គភាពជំនាញពាក់ព័ន្ធក្នុងផ្នែកនីមួយៗ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំអនុវត្តនូវបណ្តាសកម្មភាពអាទិភាពទាំងឡាយដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨នេះ។ ជាមួយគ្នានេះ បណ្តាដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសង្គមស៊ីវិល ក៏បានចូលរួមអនុវត្តការងារតាមជំនាញរបស់ខ្លួន ដើម្បីរួមចំណែកសម្រេចបាននូវទិសដៅដែលបានកំណត់នេះ។ បន្ថែមលើនេះ ផែនការយុទ្ធសាស្ត្រនេះមានលក្ខណៈពហុវិស័យសង្គតិភាព និងបំពេញឱ្យគ្នាជាមួយផែនការនិងគោលនយោបាយជាតិរបស់រាជរដ្ឋាភិបាល។

ផ្អែកលើផែនការយុទ្ធសាស្ត្រនេះ ការរៀបចំនិងអនុវត្តតាមប្រព័ន្ធ "អភិក្រមផ្អែកតាមកម្មវិធី (Programme Based Approach)" ត្រូវបានជំរុញនិងលើកទឹកចិត្តឱ្យអនុវត្ត ដោយត្រូវបញ្ចូលគ្នានូវធនធាន ដែលមានទាំងថវិកាជាតិនិងថវិកាពីដៃគូអភិវឌ្ឍន៍ ដើម្បីសម្រេចបាននូវគោលដៅរួមគ្នា។ ជាងនេះទៀត ការកសាងផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី គឺចាំបាច់ត្រូវអនុវត្តឱ្យស្របទៅនឹងផែនការយុទ្ធសាស្ត្រនេះផងដែរ។

ជាមួយគ្នានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងរៀបចំកសាង "ផែនការមេស្តីពីការអភិវឌ្ឍវិស័យកសិកម្មឆ្ពោះទៅឆ្នាំ២០៣០" ដោយបានកំណត់នូវទិសដៅគោលនយោបាយដូចខាងក្រោម៖

**ចក្ខុវិស័យ**៖ "កសិកម្មកម្ពុជាជាកសិកម្មទំនើប មានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព ដែលធានាបាននូវសន្តិសុខនិងសុវត្ថិភាពស្បៀង ព្រមទាំងអាហារូបត្ថម្ភ សម្រាប់វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ"។

**បេសកកម្ម**៖ "ផ្តល់សេវាគាំទ្រមានគុណភាពខ្ពស់ ប្រកបដោយលក្ខណៈវិទ្យាសាស្ត្របច្ចេកទេស បទដ្ឋានគតិយុត្ត សម្រាប់បម្រើឱ្យការអភិវឌ្ឍវិស័យកសិកម្មកម្ពុជាប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព"។

**គោលដៅគោលនយោបាយ**៖ "ជំរុញកំណើនកសិកម្ម និងបង្កើនការនាំចេញផលិតផលកសិកម្មប្រកបដោយគុណភាពនិងសុវត្ថិភាព តាមរយៈការលើកកម្ពស់ផលិតភាពកសិកម្ម បង្កើនតម្លៃបន្ថែម និងពង្រីកការប្រកួតប្រជែងទីផ្សារ ព្រមទាំងរក្សាបានតុល្យភាពនៃការប្រើប្រាស់ដីកសិកម្ម និងធានាការគ្រប់គ្រងធនធានព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព "។

ក្នុងឆ្នាំ២០១៨នេះ ក្រសួងនឹងរៀបចំកសាង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្នាំ២០១៩-២០២៣ ឱ្យស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលនឹងត្រូវដាក់ចេញនាពេលខាងមុខដ៏ខ្លី។

## ២. យុទ្ធសាស្ត្រចំបងៗសម្រាប់តម្រង់ទិសអភិវឌ្ឍន៍កសិកម្មសម្រាប់ឆ្នាំ២០១៨

សារៈសំខាន់របស់វិស័យកសិកម្មត្រូវបានស្តែងឱ្យឃើញ តាមរយៈក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាច្រើន ជាអាទិ៍៖ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ ក៏ដូចជាគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្កររបស់រាជរដ្ឋាភិបាល ដែលបានផ្តោតជាសំខាន់លើការជំរុញ និងលើកស្ទួយវិស័យកសិកម្ម តាមរយៈការបង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ជាមួយនឹងរបត់ថ្មី ដើម្បីឈានឆ្ពោះទៅរកការពន្លឿនកំណើនសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្រយ៉ាងឆាប់រហ័ស។ បន្ថែមលើសពីនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ដែលមានគោលដៅសំខាន់ពាក់ព័ន្ធនឹងវិស័យកសិកម្ម គឺត្រូវជំរុញការនាំចេញទំនិញកែច្នៃកសិកម្មឲ្យបាន១២% នៃបរិមាណនាំចេញសរុបនៅឆ្នាំ២០២៥។ ក្នុងន័យនេះ យើងត្រូវតែធ្វើឱ្យប្រាកដនូវរាល់គោលដៅ ក្នុងការងារអភិវឌ្ឍន៍វិស័យកសិកម្មកម្ពុជា គឺត្រូវចាប់ច្បាមនូវកាលានុវត្តភាពនេះឱ្យបាន ជាពិសេសត្រូវធ្វើឱ្យកម្ពុជាមានឧត្តមភាពប្រកួតប្រជែងទីផ្សារក្នុងស្រុក និងការនាំចេញកសិផលទាំងក្នុងតំបន់ និងពិភពលោក និងកាត់បន្ថយការនាំចូល។

ទន្ទឹមនឹងនេះ ក្រសួងក៏បានពិនិត្យឃើញថា ការអភិវឌ្ឍវិស័យកសិកម្ម មានការជាប់ពាក់ព័ន្ធដោយផ្ទាល់ និងមានលក្ខណៈប្រទាក់ក្រឡាគ្នាទៅនឹងខ្សែចង្វាក់ផលិតកម្មនិងតម្លៃផលិតផលកសិកម្ម និងការប្រកួតប្រជែងកសិផលនៅលើទីផ្សារ បើទោះបីក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះយើងបានពិនិត្យឃើញថា ការអភិវឌ្ឍវិស័យថាមពលអគ្គិសនី ការចាត់ចែងនិងវាយបណ្ដាញអគ្គិសនីមានការរីចម្រើនគួរឲ្យកត់សម្គាល់យ៉ាងណាក៏ដោយ ក៏មិនទាន់បានផ្ដល់ការទាក់ទាញដល់អ្នកវិនិយោគពីខាងក្រៅទៅលើការផ្គត់ផ្គង់សម្ភារកសិកម្ម និងការវេចខ្ចប់ផលិតផលកសិកម្មនៅឡើយ។

បន្ថែមលើសពីនេះទៅទៀត ការផ្ដល់សេវាបច្ចេកទេស និងកែលម្អធាតុចូលកសិកម្ម គប្បីធ្វើឡើងដោយមានចំណងទាក់ទងដ៏ខ្លាំងក្លារវាងតួអង្គសំខាន់ៗមួយចំនួនគឺ ស្ថាប័នដែលមានការជាប់ពាក់ព័ន្ធខាងលើ កសិករ ស្ថាប័នស្រាវជ្រាវ និងស្ថាប័នផ្សព្វផ្សាយកសិកម្ម។ យន្តការដែលត្រូវប្រទាក់ក្រឡាគ្នា រួមមានគោលនយោបាយ និងបទដ្ឋានគតិយុត្ត រចនាសម្ព័ន្ធនិងអង្គការចាត់តាំងស្ថាប័ន និងប្រតិបត្តិការផ្ដល់សេវាផ្សព្វផ្សាយ។ ចំពោះការចាត់ចែងវិធីសាស្ត្រនៃការផ្សព្វផ្សាយកសិកម្មត្រូវ៖ (១) អនុវត្តទៅតាមអភិក្រមប្រព័ន្ធកសិកម្មចម្រុះ សម្រាប់ការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាព (២) គាំទ្រដល់កសិករគ្រប់ប្រភេទ តាមរយៈការលើកកម្ពស់អភិក្រមដែលបំពេញទៅតាមតម្រូវការទីផ្សារនិងអ្នកទទួលផល នៅក្នុងដំណើរការជ្រើសរើសបច្ចេកវិទ្យាថ្មីៗ និងការអនុវត្តនានាដែលនាំមកនូវការបង្កើនទិន្នផល និងទទួលបានប្រាក់ចំណេញខ្ពស់ (៣) សហការជាមួយគ្រប់ក្រុមកសិករទាំងអស់ និងគិតគូអំពីសារៈសំខាន់នៃចំណេះដឹង និងគំនិតច្នៃប្រឌិតថ្មីៗដល់កសិករនៅមូលដ្ឋាន (៤) លើកកម្ពស់ការផ្ដល់បច្ចេកវិទ្យាព័ត៌មាន និងសារទូរគមនាគមន៍នៅតាមជនបទ និង(៥) វិនិយោគលើការកែលម្អគុណភាពប្រធានបទ និងធ្វើបច្ចុប្បន្នភាពសម្ភារផ្សព្វផ្សាយជាប្រចាំ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងការងារអាទិភាពរបស់កសិករ។

ដើម្បីធានាឲ្យមានទីផ្សារតម្លៃកសិផលបានល្អសម្រាប់កសិករក្នុងរយៈពេលវែង ក៏ដូចជាការធានាបាននូវផលប្រយោជន៍សម្រាប់កសិករ ការលើកទឹកចិត្តកសិករដែលជាអ្នកផលិត និងលើកស្ទួយផលិតផលកសិកម្មរបស់ជាតិ គួរត្រូវបានពិនិត្យពិចារណាលើការកែលម្អរចនាសម្ព័ន្ធដឹកជញ្ជូន និងបែបបទនៃការវិនិយោគលើការរៀបចំចាត់ចែងរបស់សហព័ន្ធស្រូវ អង្ករ ក្នុងការនាំផលិតផលកសិកម្មចេញពីកម្ពុជា ដោយត្រូវផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនឹងការផ្គត់ផ្គង់ពូជសុទ្ធជូនដល់កសិករ ដែលនឹងទទួលបានជំនឿជឿជាក់មកវិញពីអ្នកទិញ។

ទន្ទឹមនឹងបញ្ហាប្រឈមដូចបានជម្រាបជូនខាងលើ ក្រសួងពាក់ព័ន្ធគួរធ្វើការរួមគ្នាលើការតម្រង់ទិសលើការវិនិយោគក្នុងរយៈពេលមធ្យម និងវែងទៅលើហេដ្ឋារចនាសម្ព័ន្ធ ទឹក ផ្លូវ ភ្លើង បម្រើដល់វិស័យកសិកម្មឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ដើម្បីបម្រើឲ្យការនាំចេញ។ ដោយឡែកការរៀបចំផែនការគ្រប់គ្រងដីកសិកម្ម ក៏ត្រូវការចាំបាច់មានការចូលរួមយ៉ាងពេញលេញពីសំណាក់អ្នកពាក់ព័ន្ធ ដូចជាការកំណត់ប្រភេទដី និងដំណាំកសិកម្ម សក្ដានុពលធនធានធម្មជាតិដូចជា ទឹកនិងព្រៃឈើ តំបន់ការពារ និងការរៀបចំដែនដី។ល។ ស្ថិតនៅក្នុងសភាពការណ៍ចំពោះមុខនេះ យើងអាចកំណត់ប្រភេទដាំដុះដំណាំកសិកម្ម ទៅតាមតំបន់នីមួយៗជាបឋមបានដែរ ដែលអាចយកជាមូលដ្ឋានឈានទៅដល់ការតម្រង់ទិស លើការអភិវឌ្ឍវិស័យនាពេលខាងមុខរួមមាន៖

(១) ការដាំដុះដំណាំស្រូវ និងការធ្វើវារីវប្បកម្ម សម្រាប់បម្រើដល់ការនាំចេញ គួរកំណត់យកតំបន់ដែលមានប្រភពទឹកគ្រប់គ្រាន់ ឋិតថេរ និងវិសាលភាពដីដាំដុះមានភាពទូលំទូលាយ ដូចជាផ្នែកខាងក្រោមតាមបណ្ដាស្ទឹងសំខាន់ៗមួយចំនួន ជាពិសេសតំបន់អាងទឹកដែលស្ថិតនៅជុំវិញបឹងទន្លេសាប និងទន្លេមេគង្គនៃខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ និងតាកែវ ។

(២) ការដាំដុះដំណាំកសិ-ឧស្សាហកម្ម ការចិញ្ចឹមសត្វ សម្រាប់បម្រើដល់ការនាំចេញគួរកំណត់យកតំបន់ខ្ពង់រាបតំបន់ជុំវិញទន្លេសាបនិងទន្លេមេគង្គ។

(៣) ការធ្វើកសិកម្មចម្រុះ ដូចជាការផលិតបន្លែគ្រប់មុខ និងការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ គួរតម្រង់ទិសទៅលើតំបន់ដែលមានការខ្សត់ប្រភពទឹកលើដី ដែលគួរអនុវត្តនៅខេត្តគោលដៅមួយចំនួនដូចជាខេត្តកំពត តាកែវ ស្វាយរៀង ព្រៃវែង កណ្ដាល មណ្ឌលគិរី ត្បូងឃ្មុំ និងកំពង់ចាមជាដើម។

ម្យ៉ាងទៀតក្នុងគោលបំណងលើកកម្ពស់ប្រាក់ចំណូលរបស់កសិករ ស្របតាមកំណើនសេដ្ឋកិច្ចកម្ពុជាដែលកំពុងកើនឡើងប្រកបដោយស្ថិរភាព និងមានតម្លៃថេរក្នុងរង្វង់៧%ក្នុងមួយឆ្នាំ រួមទាំងការកាត់បន្ថយការធ្វើចំណាកស្រុករបស់កសិករដែលខ្វះមធ្យោបាយផលិត ជាពិសេសកសិករដែលមានផ្ទៃដីតិចនោះ ក្រសួងពិនិត្យឃើញថា ការអភិវឌ្ឍកសិកម្មចម្រុះគឺជាមធ្យោបាយតែមួយគត់ដែលត្រូវកំណត់យកមកអនុវត្តក្នុងរយៈខ្លីនិងមធ្យម។

ដើម្បីមានលទ្ធភាពឈានទៅដល់ការអនុវត្តពេញលេញ នូវគោលនយោបាយធ្វើកំណែទម្រង់លើវិស័យកសិកម្ម ក្រសួងនឹងផ្ដោតទៅលើសកម្មភាពជាអាទិភាពមួយចំនួនដូចខាងក្រោមៈ

១. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ដោយបំពាក់បច្ចេកវិទ្យាទំនើបក្នុងការផ្គត់ផ្គង់ទឹក (ពិសេសការតម្លើងប្រព័ន្ធដំណក់ទឹក) សម្រាប់បម្រើដល់ការដាំដុះដំណាំរួមផ្សំ សាកវប្បកម្ម ដំណាំបន្លែ និងចិញ្ចឹមសត្វ នៅតាមសហគមន៍/សហករណ៍កសិកម្ម ដែលត្រូវបានបង្កើតឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាពិសេសនៅលើតំបន់កសិករក្រីក្រ និងមានដីតិច។ ផលិតកម្មកសិកម្មត្រូវអនុវត្តតាមគោលការណ៍ GAP ដើម្បីសុវត្ថិភាពចំណីអាហារជាចាំបាច់។

២. សហការជាមួយក្រសួងពាក់ព័ន្ធក្នុងការកសាងតភ្ជាប់ប្រឡាយជើងក្អែបជូនសហគមន៍/សហករណ៍កសិកម្ម ដើម្បីឈានទៅដល់ការប្រើប្រាស់ទឹកបានពេញលេញនៅលើប្រព័ន្ធស្រោចស្រពមួយចំនួន ដែលបានធ្វើការវិនិយោគដ៏ច្រើនសន្ធឹកសន្ធាប់ដោយរាជរដ្ឋាភិបាល និងបម្រើដល់ការធ្វើប្រពលវប្បកម្មដំណាំស្រូវ និងការធ្វើវារីវប្បកម្មឱ្យទទួលបានជោគជ័យ និងប្រសិទ្ធភាព។

៣. បង្កើនការយកចិត្តទុកដាក់ទៅលើការស្រាវជ្រាវនិងផ្សព្វផ្សាយកសិកម្ម សំដៅបង្កើនទិន្នផលដំណាំ លើកកម្ពស់គុណភាពផលិតផល ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដោយផ្សារភ្ជាប់ជាមួយផលិតកម្មកសិកម្មតាមកិច្ចសន្យា និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងនិងប្រើប្រាស់ដីប្រកបដោយនិរន្តរភាព។

៤. ជំរុញការចិញ្ចឹមសត្វឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្ដិសិទ្ធភាព តាមរយៈការពង្រឹងប្រសិទ្ធភាពការស្រាវជ្រាវនិងផ្សព្វផ្សាយ ការពង្រីកការចិញ្ចឹមសត្វ ការចែកចាយនិងបង្កាត់ពូជសត្វដែលមានតម្លៃនៅលើទីផ្សារ បង្កើនសមត្ថភាពបង្ការ ទប់ស្កាត់ជំងឺឆ្លងសត្វ ដើម្បីធានាបានការផ្គត់ផ្គង់សត្វ សាច់សត្វ ប្រកបដោយអនាម័យ សុវត្ថិភាព និងបង្កើនសក្ដានុពលនៃការនាំចេញ។

៥. ជំរុញការអភិវឌ្ឍវារីវប្បកម្ម (កើន២០%ក្នុងមួយឆ្នាំ) នៅតាមតំបន់ដែលមានប្រភពទឹកគ្រប់គ្រាន់ និងបង្កើនការការពារនិងអភិរក្សធនធានជលផល ដើម្បីធានាឲ្យបាននូវនិរន្តភាពធនធានជលផល ព្រមទាំងកែលម្អគុណភាព និងសុវត្ថិភាពផល ផលិតផលជលផល សម្រាប់ការប្រើប្រាស់ក្នុងស្រុកនិងនាំចេញ។

៦. ជំរុញការដាំនិងស្ដារព្រៃឈើឡើងវិញ (ពិសេសការសហការដៃគូជាមួយផ្នែកឯកជន) ព្រមទាំងពង្រីកនិងពង្រឹងសហគមន៍ព្រៃឈើឱ្យមាននិរន្តភាព (ការរកមុខរបរបន្ថែម ដូចជា ការចិញ្ចឹមសត្វ ដាំដុះដំណាំមានទីផ្សារខ្ពស់ជាដើម កាត់បន្ថយការពឹងផ្អែកខ្លាំងលើព្រៃឈើក្នុងសហគមន៍) និង

៧. សិក្សាពិនិត្យលើលទ្ធភាពធ្វើកំណែទម្រង់រចនាសម្ព័ន្ធរបស់ក្រសួង ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្ដល់សេវាគាំទ្រ និងពង្រឹងសមត្ថភាពផ្នែកអប់រំ និងបណ្ដុះបណ្ដាលសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មប្រកបដោយនិរន្តរភាព។

ក្រសួងបានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលទាំងឡាយដែលសម្រេចបានក្នុងឆ្នាំ២០១៧នេះ ដែលបានកើតចេញពីការខិតខំប្រឹងប្រែងរួមគ្នារវាងក្រសួង ស្ថាប័ននានា និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កន្លងមក។ សមិទ្ធផលដែលសម្រេចបាននេះ គឺបានមកពីការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល មន្ត្រីរាជការគ្រប់